លេខ ៥៩ ចេញផ្សាយថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៦

# ព្រឹត្តិបត្រព័ត៌មាន

## ប្រចាំខែឧសភា ឆ្នាំ២០២៦

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## មាតិកា


- ទិន្នន័យប្រតិបត្តិការក្នុងវិស័យបរធនបាលកិច្ច គិតត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៦.......................................... ទំព័រទី២
- កិច្ចប្រជុំរវាងថ្នាក់ដឹកនាំ **ន.ប.ធ.** ជាមួយសិស្សសាការីដែលបានស្នើសុំចុះទស្សនកិច្ចសិក្សាស្រាវជ្រាវ សាកសួរព័ត៌មានមួយចំនួនពាក់ព័ន្ធនឹងប្រធានបទរបាយកាណ៍កម្មសិក្សា អំពីការចុះបញ្ជីអចលនវត្ថុតាមរយៈលិខិតបរធនបាលកិច្ច.............................. ទំព័រទី២
- សកម្មភាពមន្ត្រីជំនាញនៃ **ន.ប.ធ.** ត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្មនៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តកោះកុង.............................. ទំព័រទី៣
- សកម្មភាពមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ដែលស្នើសុំបន្តអាជ្ញាបណ្ណពី **ន.ប.ធ.** ......................................................... ទំព័រទី៣
- សិក្ខាសាលាស្តីពី "យន្តការ និងអត្ថប្រយោជន៍របស់បរធនបាលកិច្ច" ................................................................. ទំព័រទី៣
- វគ្គបណ្តុះបណ្តាលស្តីពី "នីតិប្រតិបត្តិហិរញ្ញប្បទានខ្សែច្រវាក់តម្លៃកសិកម្ម គម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម"........................................................ ទំព័រទី៤
- កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**).......................................... ទំព័រទី៤
- កិច្ចប្រជុំពិនិត្យវឌ្ឍនភាពនៃការអនុវត្តគម្រោង និងពិភាក្សាត្រៀមរៀបចំសម្រាប់បេសកកម្មពិនិត្យការអនុវត្តគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (Review Mission ADB) ក្នុងក្របខ័ណ្ឌនៃគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)................................................. ទំព័រទី៥
- សិក្ខាសាលាលើកកម្ពស់ការយល់ដឹងដល់បុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច និងធានារ៉ាប់រងកម្ពុជាស្តីពី "ប្រភេទ និងហានិភ័យការឆបោកតាមប្រព័ន្ធអនឡាញ"............................. ទំព័រទី៥
- សកម្មភាពមន្ត្រីជំនាញរបស់ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ក្រុមហ៊ុន ប្រូវីដិន ឃែភីថល ឯ.ក ដើម្បីត្រួតពិនិត្យការបំពេញលក្ខខណ្ឌអាជ្ញាបណ្ណក្រុមហ៊ុនបរធនបាលសម្រាប់ប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម...................................... ទំព័រទី៥
- កិច្ចប្រជុំក្របខ័ណ្ឌគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល (**គ.ស.ធ.ឌ.**) និងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (**គ.ស.ហ.**) ដើម្បីពិនិត្យលើ "សេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍធុរកិច្ចថ្មី ២០២៦-២០៣០".............. ទំព័រទី៦
- សកម្មភាពចូលរួមអមដំណើរប្រតិភូធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដើម្បីចូលរួមសម្របសម្រួលនិងពិនិត្យវឌ្ឍនភាពរបស់សហគមន៍កសិកម្ម នៅខេត្តកំពង់ធំ និងខេត្តសៀមរាប................ ទំព័រទី៦
- សិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ២០២៥-២០៣០ ផ្នែកវិស័យហិរញ្ញវត្ថុមិនមែនធនាគារ........... ទំព័រទី៧
- សកម្មភាពមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្ម ដែលស្ថិតនៅខេត្តតាកែវ ................................................................. ទំព័រទី៧
- ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ស្តីពី "ការលើកកម្ពស់ការយល់ដឹង និងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" រវាង **ន.ប.ធ.** និងសាកលវិទ្យាល័យធនធានមនុស្ស (**ស.ធ.ម.**)........................... ទំព័រទី៧
- កិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សាស្តីពី "ការពិនិត្យឡើងវិញនិងការវិភាគមុខងារនិងរចនាសម្ព័ន្ធ **អ.ស.ហ.** ពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ និងបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ".. ទំព័រទី៨
- សិក្ខាសាលាចែករំលែកបទពិសោធស្តីពី "វឌ្ឍនភាព និងទិសដៅបរិវត្តកម្មឌីជីថលនៅកម្ពុជា"................................ទំព័រទី៨
- កិច្ចប្រជុំពិនិត្យពិភាក្សាលើការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់និងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈឯកទេសនៃ**កសហវ** ................................................................. ទំព័រទី៩




អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh   www.facebook.com/trustregulatorcambodia   (855) 23 237 888

- ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករធានារ៉ាប់រងកម្ពុជា និងវិទ្យាស្ថានធានារ៉ាប់រងនិងហិរញ្ញវត្ថុ នៃប្រទេសអូស្ត្រាលី និងនូវែលហ្សេឡង់ (ANZIIF)៉.......................... ទំព័រទី៩
- កិច្ចប្រជុំជាមួយក្រុមបេសកកម្ម JICA លើការរៀបចំផែនការស្ទង់មតិលម្អិត សម្រាប់គម្រោងជំនួយបច្ចេកទេស ដំណាក់កាលទី២ របស់ធនាគារជាតិនៃកម្ពុជា.......................................ទំព័រទី៩
- កម្មវិធីបញ្ជ្រាបការយល់ដឹងស្តីពី "ការដាក់ឱ្យអនុវត្តចំណាយវិនិយោគថវិកាថ្នាក់ជាតិក្នុងប្រទេសតាម FMIS និងការកត់ត្រាទិន្នន័យចំណាយគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ក្នុង FMIS ជូនក្រសួង-ស្ថាប័ន និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធពេញលេញ"...................................................ទំព័រទី១០
- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារទីស្នាក់ការកណ្តាលថ្មីរបស់អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ .................................................................ទំព័រទី១០
- សកម្មភាពរបស់មន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ក្រុមហ៊ុន ឡាយអិន ត្រាស់ (**ខេមបូឌា**) ឯ.ក ដែលស្នើសុំបន្តអាជ្ញាបណ្ណពី **ន.ប.ធ.** ...................................... ទំព័រទី១០
- សកម្មភាពមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ក្រុមហ៊ុន អឺរ៉ាស៊ា ត្រាស ឯ.ក ដែលស្នើសុំផ្លាស់ប្តូរទីស្នាក់ការថ្មី.................................................................. ទំព័រទី១១
- វេទិកាវិនិយោគសកលអាស៊ាន.............................ទំព័រទី១១
- កម្មវិធី "Asia Tech x Singapore ប្រចាំឆ្នាំ២០២៦" ទំព័រទី១១
- សិក្ខាសាលាផ្សព្វផ្សាយអំពី "គោលការណ៍ណែនាំស្តីពីវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនក្នុងវិស័យបរធនបាលកិច្ច និង សេចក្តីណែនាំស្តីពីវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនក្នុងក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម".... ទំព័រទី១២
- សកម្មភាពចូលរួមអមដំណើរ ទស្សនកិច្ចរបស់ក្រុមប្រឹក្សាភិបាល និងប្រតិភូរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) លើសកម្មភាពជំរុះបន្លែរបស់សមាជិកសហគមន៍កសិកម្មសុវត្ថិភាពធម្មជាតិដែលទទួលហិរញ្ញប្បទានពីគម្រោង ACSEP ក្នុងខេត្តសៀមរាប.. ទំព័រទី១២
- សកម្មភាពមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្ម ដែលស្ថិតនៅខេត្តតាកែវ, ខេត្តកំពង់ចាម, ខេត្តកណ្តាលនិងរាជធានីភ្នំពេញ...... ទំព័រទី១៣
- កិច្ចប្រជុំបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)............................. ទំព័រទី១៣
- សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់កសិធុរកិច្ចសមាជិកសហគមន៍កសិកម្ម និងកសិករចិញ្ចឹមមាន់"..ទំព័រទី១៤


## ទិន្នន័យប្រតិបត្តិការក្នុងវិស័យបរធនបាលកិច្ច គិតត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៦

និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) សូមជូននូវទិន្នន័យប្រតិបត្តិការក្នុងវិស័យបរធនបាលកិច្ច គិតត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៦។

| ប្រភេទបរធនបាលកិច្ច | ចំនួន | ទំហំបរធន |
|---|---|---|
| បរធនបាលកិច្ចសាធារណៈ | ៣ | $ ១២១,៦៣៨,៩១០ |
| បរធនបាលកិច្ចហិរញ្ញវត្ថុ | ៩ | $ ៥០៥,៦២៧,៤៥២ |
| បរធនបាលកិច្ចពាណិជ្ជកម្ម | ១,៨៨៧ | $ ២,០៥២,២៥២,៥៥៤.១២ |
| បរធនបាលកិច្ចសង្គម | ៣ | $ ១,៩៩៨,៥៣១.៤៩ |
| បរធនបាលកិច្ចបុគ្គល | ១០ | $ ២,៧៤៥,១៩២.៤៨ |
| **សរុប** | **១,៩១២** | **$ ២,៦៨៤,២៦២,៦៤០.០៩** |

| បរធនបាលដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត និងក្រុមហ៊ុនទទួលបានការទទួលស្គាល់ | ចំនួន |
|---|---|
| ក្រុមហ៊ុនបរធនបាល | ១៦ |
| ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬរក្សាទុក (Escrow Services) នៅក្នុងវិស័យបរធនបាលកិច្ច | ២៩ |
| បរធនបាលរូបវន្តបុគ្គលឯករាជ្យ | ២៩ |
| បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល | ៤៣ |
| ក្រុមហ៊ុនវាយតម្លៃ | ១៩ |
| ក្រុមហ៊ុនផ្តល់សេវាសវនកម្ម | ១៥ |

**តារាង៖** ទិន្នន័យប្រតិបត្តិការក្នុងវិស័យបរធនបាលកិច្ច គិតត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៦។

## កិច្ចប្រជុំរវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយសិស្សសាការីដែលបានស្នើសុំចុះទស្សនកិច្ចសិក្សាស្រាវជ្រាវ សាកសួរព័ត៌មានមួយចំនួនពាក់ព័ន្ធនឹងប្រធានបទរបាយការណ៍កម្មសិក្សា អំពីការចុះបញ្ជីអចលនវត្ថុតាមរយៈលិខិតបរធនបាលកិច្ច

នាព្រឹកថ្ងៃចន្ទ ៣រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ ត្រូវនឹងថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច** អមដោយសហការីបានជួបប្រជុំជាមួយជាមួយសិស្សសាការី ដែលបានស្នើសុំចុះទស្សនកិច្ចសិក្សាស្រាវជ្រាវ សាកសួរព័ត៌មានមួយចំនួនពាក់ព័ន្ធនឹងប្រធានបទរបាយការណ៍កម្មសិក្សា អំពីការចុះបញ្ជីអចលនវត្ថុតាមរយៈលិខិតបរធនបាលកិច្ច ដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាព នៃការបណ្តុះ-

ទំព័រទី២

បណ្តាល ដោយការផ្សារភ្ជាប់ទ្រឹស្តី និងការអនុវត្តជាក់ស្តែងឱ្យស្របតាមលក្ខណៈបច្ចេកទេស នៅទីស្តីការនៃ **ន.ប.ធ.**។



**រូបភាព៖** កិច្ចប្រជុំរវាងថ្នាក់ដឹកនាំ **ន.ប.ធ.** ជាមួយសិស្សសាកាវីដែលបានស្នើសុំចុះទស្សនកិច្ចសិក្សាស្រាវជ្រាវ សាកសួរព័ត៌មានមួយចំនួនពាក់ព័ន្ធនឹងប្រធានបទរបាយកាណ៍កម្មសិក្សា អំពីការចុះបញ្ជីអចលនវត្ថុតាមរយៈលិខិតបរធនបាលកិច្ច។

## សកម្មភាពមន្ត្រីជំនាញនៃ ន.ប.ធ. ត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្មនៅរាជធានី-ភ្នំពេញ ខេត្តកណ្តាល និងខេត្តកោះកុង

ចាប់ពីថ្ងៃចន្ទ ១១កើត ដល់ថ្ងៃព្រហស្បតិ៍ ១៤កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៧-៣០ ខែមេសា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាត និងការចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក ឆយ ច័ន្ទមករា ប្រធានការិយាល័យគ្រប់គ្រងបរធនបាលកិច្ចសាធារណៈ និងពាណិជ្ជកម្ម** និងលោក **អ៊ឹង ឡេង ប្រធានការិយាល័យគ្រប់គ្រងបរធនបាលកិច្ចហិរញ្ញវត្ថុ នៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច** បានដឹកនាំមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្ម ដែលស្ថិតនៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តកោះកុង ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ចពាក់ព័ន្ធ និងកំពុងធ្វើប្រតិបត្តិការដោយក្រុមហ៊ុនបរធនបាលដែលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.**។



**រូបភាព៖** សកម្មភាពមន្ត្រីនៃ **ន.ប.ធ.** ត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្ម ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ចពាក់ព័ន្ធ និងកំពុងធ្វើប្រតិបត្តិការដោយក្រុមហ៊ុនបរធនបាលដែលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** នៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តកោះកុង។

## សកម្មភាពមន្ត្រីជំនាញនៃ ន.ប.ធ ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ដែលស្នើសុំបន្តអាជ្ញាបណ្ណពី ន.ប.ធ.

នាព្រឹកថ្ងៃពុធ ៥រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ ត្រូវនឹងថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក រិន វឌ្ឍា ប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ចនៃ ន.ប.ធ.** បានដឹកនាំមន្ត្រីជំនាញចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំបន្តអាជ្ញាបណ្ណប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ចសម្រាប់ប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម។



**រូបភាព៖** សកម្មភាពមន្ត្រីជំនាញនៃ **ន.ប.ធ** ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ដែលស្នើសុំបន្តអាជ្ញាបណ្ណពី **ន.ប.ធ.**។

## សិក្ខាសាលាស្តីពី "យន្តការ និងអត្ថប្រយោជន៍របស់បរធនបាលកិច្ច"

នាព្រឹកថ្ងៃព្រហស្បតិ៍ ៦រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៦ និយ័តករបរ-ធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យជាតិគ្រប់គ្រង បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "យន្តការ និងអត្ថប្រយោជន៍របស់បរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ណៃ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច និង **ឯកឧត្តមបណ្ឌិត កុយ កុសល ព្រឹទ្ធបុរសនៃមហាវិទ្យាល័យហិរញ្ញវត្ថុ និងគណនេយ្យនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង** នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរ-ធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បី

ធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ,សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង។



រូបភាព៖ សិក្ខាសាលាស្តីពី "យន្តការ និងអត្ថប្រយោជន៍របស់បរធនបាលកិច្ច"។

## វគ្គបណ្តុះបណ្តាលស្តីពី "នីតិប្រតិបត្តិហិរញ្ញប្បទានខ្សែច្រវាក់តម្លៃកសិកម្ម គម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម"

នាថ្ងៃសុក្រ ៧រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ ត្រូវនឹងថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៦ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្មសម្រាប់សមាសភាគទី១ (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "នីតិប្រតិបត្តិហិរញ្ញប្បទានខ្សែច្រវាក់តម្លៃកសិកម្ម គម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1 នៅសណ្ឋាគារភ្នំពេញ។

កម្មវិធីនេះ រៀបចំឡើងក្នុងគោលបំណងផ្តល់ចំណេះដឹងដល់មន្ត្រីនៃគ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារលើនីតិវិធីប្រតិបត្តិហិរញ្ញប្បទានខ្សែច្រវាក់តម្លៃកសិកម្ម, ផ្តល់ចំណេះដឹងដល់មន្ត្រីនៃគ្រឹះស្ថានហិរញ្ញវត្ថុនិងធនាគារលើការបំពេញទម្រង់ព័ត៌មានគ្រប់គ្រងផលប៉ះពាល់បរិស្ថាននិងសង្គម ដើម្បីជួយដល់មន្ត្រីឥណទានក្នុងការពិនិត្យ និងការរៀបចំឯកសាឥណទានដល់អតិថិជនគោលដៅរបស់គម្រោង។

កម្មវិធីនេះ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP-PIU1, តំណាងអង្គភាពគ្រប់គ្រងគម្រោងមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, តំណាងសាជីវកម្មធានាឥណទានកម្ពុជា (CGCC), គ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារទាំង ៥ រួមមាន៖ ធនាគារប្រៃសណីយ៍កម្ពុជា, ធនាគារហ្វីលីព ភីអិលស៊ី,

រួមមាន៖ ធនាគារប្រៃសណីយ៍កម្ពុជា, ធនាគារហ្វីលីព ភីអិលស៊ី, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (**ខេមបូឌា**) ភីអិលស៊ី, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេអឹមខេ ភីអិលស៊ី និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត។



រូបភាព៖ វគ្គបណ្តុះបណ្តាលស្តីពី "នីតិប្រតិបត្តិហិរញ្ញប្បទានខ្សែច្រវាក់តម្លៃកសិកម្ម គម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម"។

## កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃសុក្រ ៧រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ ត្រូវនឹងថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងស្តីពីការបង្កើតវិទ្យាស្ថានហិរញ្ញវត្ថុមិនមែនធនាគារ, សេចក្តីព្រាងអនុក្រឹត្យស្តីពី "ប្រភេទយានយន្តដែលត្រូវមានការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តជាកាតព្វកិច្ច" និងសេចក្តីព្រាងអនុក្រឹត្យស្តីពី "ការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិអភិវឌ្ឍវិស័យធានារ៉ាប់រង" របស់និយ័តករធានារ៉ាប់រងកម្ពុជា ក្រោមការដឹកនាំរបស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធាន អ.ស.ហ.** តាមរយៈប្រព័ន្ធអនឡាញ (Zoom)។



រូបភាព៖ កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។

## កិច្ចប្រជុំពិនិត្យវឌ្ឍនភាពនៃការអនុវត្តគម្រោង និងពិភាក្សាត្រៀមរៀបចំសម្រាប់បេសកកម្មពិនិត្យការអនុវត្តគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (Review Mission ADB) ក្នុងក្របខ័ណ្ឌនៃគម្រោងប្រកួតប្រជែងខ្សែ-ច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)

នារសៀលថ្ងៃចន្ទ ១០រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ ត្រូវនឹងថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាពទី១ (PIU1), **លោក ប៉ូ សំអាង ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1** អមដោយសហការី និងទីប្រឹក្សាគម្រោង បានចូលរួមកិច្ចប្រជុំពិនិត្យវឌ្ឍនភាពនៃការអនុវត្តគម្រោង និងពិភាក្សាត្រៀមរៀបចំសម្រាប់បេសកកម្មពិនិត្យការអនុវត្តគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (Review Mission ADB) ក្នុងក្របខ័ណ្ឌនៃគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)។

កិច្ចប្រជុំនេះ ត្រូវបានរៀនចំឡើងក្នុងគោលបំណងដើម្បីការពិនិត្យអំពីវឌ្ឍនភាពនៃការអនុវត្តគម្រោងរបស់អង្គភាពអនុវត្តគម្រោង ACSEP-PIU1-PIU2 & PIU3 និងត្រៀមរៀបចំសម្រាប់បេសកកម្មពិនិត្យការអនុវត្តគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (Review Mission ADB) ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៦ នៅខេត្តគោលដៅរបស់គម្រោង។ កិច្ចប្រជុំនេះត្រូវបានប្រព្រឹត្តទៅនៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។



រូបភាព៖ កិច្ចប្រជុំពិនិត្យវឌ្ឍនភាពនៃការអនុវត្តគម្រោង និងពិភាក្សាត្រៀមរៀបចំសម្រាប់បេសកកម្មពិនិត្យការអនុវត្តគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (Review Mission ADB) ក្នុងក្របខ័ណ្ឌនៃគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)។

## សិក្ខាសាលាលើកកម្ពស់ការយល់ដឹងដល់បុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច និងធានារ៉ាប់រងកម្ពុជាស្តីពី "ប្រភេទ និងហានិភ័យការឆបោកតាមប្រព័ន្ធអនឡាញ"

នាព្រឹក ថ្ងៃអង្គារ ១១រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ ត្រូវនឹងថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៦ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**, បានចូលរួមជាអធិបតីជាមួយ **លោក ង៉ោ ជាឡែន អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (**អ.ស.ហ.**) ក្នុងសិក្ខាសាលាលើកកម្ពស់ការយល់ដឹងដល់បុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច និងធានារ៉ាប់រងកម្ពុជាស្តីពី "ប្រភេទ និងហានិភ័យការឆបោកតាមប្រព័ន្ធអនឡាញ"នៅទីស្តីការ **អ.ស.ហ.**។ សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលដៅដើម្បីផ្សព្វផ្សាយ ចែករំលែកបទពិសោធន៍ និងចំណេះដឹងផ្នែកបទល្មើសបច្ចេកវិទ្យាដល់បុគ្គលរាយការណ៍ក្នុងវិស័យទាំង ២ (ពីរ) ដើម្បីចូលរួមសហការក្នុងការប្រឆាំងបទល្មើសនេះដែលជាភារកិច្ចរបស់យើងទាំងអស់គ្នាជាកិច្ចការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ការប្រឆាំងបទល្មើសនេះអនុលោមតាមអនុសាសន៍ទី១ ដល់ទី៨ របស់ក្រុមការងារហិរញ្ញវត្ថុ។



រូបភាព៖ សិក្ខាសាលាលើកកម្ពស់ការយល់ដឹងដល់បុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច និងធានារ៉ាប់រងកម្ពុជាស្តីពី "ប្រភេទ និងហានិភ័យការឆបោកតាមប្រព័ន្ធអនឡាញ"។

## សកម្មភាពមន្ត្រីជំនាញរបស់ ន.ប.ធ. ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ក្រុមហ៊ុន ប្រូវីដិន ឃែភីថល ឯ.ក ដើម្បីត្រួតពិនិត្យការបំពេញលក្ខខណ្ឌអាជ្ញាបណ្ណក្រុមហ៊ុនបរធនបាលសម្រាប់ប្រតិបត្តិការបរធកិច្ចពាណិជ្ជកម្ម

នារសៀលថ្ងៃអង្គារ ១១រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក

នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោកស្រី ស៊ិន សុមាល័យ អនុប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ចនៃ ន.ប.ធ.** បានដឹកនាំមន្ត្រីជំនាញចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ក្រុមហ៊ុន ប្រូវីដិន ឃែភីថល ឯ.ក ដើម្បីត្រួតពិនិត្យការបំពេញលក្ខខណ្ឌអាជ្ញាបណ្ណក្រុមហ៊ុនបរធនបាលសម្រាប់ប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម។



រូបភាព៖ សកម្មភាពមន្ត្រីជំនាញរបស់ ន.ប.ធ. ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ក្រុមហ៊ុន ប្រូវីដិន ឃែភីថល ឯ.ក ដើម្បីត្រួតពិនិត្យការបំពេញលក្ខខណ្ឌអាជ្ញាបណ្ណក្រុមហ៊ុនបរធនបាលសម្រាប់ប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម។

## កិច្ចប្រជុំក្របខ័ណ្ឌគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល (គ.ស.ធ.ឌ.) និងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.) ដើម្បីពិនិត្យលើ "សេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍធុរកិច្ចថ្មី ២០២៦ ដល់ ២០៣០"

នាព្រឹកថ្ងៃពុធ ១២រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ ត្រូវនឹងថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកនៃគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល បានអញ្ជើញចូលរួមកិច្ចប្រជុំក្របខ័ណ្ឌគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល (**គ.ស.ធ.ឌ.**) និងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (**គ.ស.ហ.**) ដើម្បីពិនិត្យលើ "សេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍធុរកិច្ចថ្មី ២០២៦ ដល់ ២០៣០" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) និងជាប្រធាន គ.ស.ធ.ឌ.** ព្រមទាំងមានការអញ្ជើញចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធផងដែរ។



រូបភាព៖ កិច្ចប្រជុំក្របខ័ណ្ឌគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល (គ.ស.ធ.ឌ.) និងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.) ដើម្បីពិនិត្យលើ "សេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍធុរកិច្ចថ្មី ២០២៦ ដល់ ២០៣០"។

## សកម្មភាពចូលរួមអមដំណើរប្រតិភូធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដើម្បីចូលរួមសម្របសម្រួលនិងពិនិត្យវឌ្ឍនភាពរបស់សហគមន៍កសិកម្ម នៅខេត្តកំពង់ធំ និងខេត្តសៀមរាប

នាថ្ងៃព្រហស្បតិ៍ ១៣រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ ត្រូវនឹងថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៦ ដោយទទួលបានការចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងនៃគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សមាសភាគទី១ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, **លោក សួន សុភា អនុប្រធានក្រុមទីប្រឹក្សាគម្រោង ACSEP-PIU1 និងកញ្ញា កេត ស្រីនិច អនុប្រធានការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍ទីផ្សារ និងជាមន្ត្រីឥណទាននៃផ្នែកប្រតិបត្តិការរបស់គម្រោង ACSEP-PIU1** អមដោយសហការី បានអញ្ជើញចូលរួមអមដំណើរប្រតិភូធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដើម្បីចូលរួមសម្របសម្រួលនិងពិនិត្យវឌ្ឍនភាពរបស់សហគមន៍កសិកម្មចំនួន ២ រួមមាន៖ សហគមន៍កសិកម្មទំនើបប្រាសាទសំបូររុងរឿង ខេត្តកំពង់ធំ និងសហគមន៍កសិកម្មបន្លែសុវត្ថិភាពធម្មជាតិ ខេត្តសៀមរាប ដែលទទួលបានហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីត្រៀមសម្រាប់ទស្សនកិច្ចរបស់ក្រុមប្រឹក្សាភិបាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នាពេលខាងមុខនេះ។

បេសកកម្មនេះ ដឹកនាំ**ដោយ លោកស្រី Yasmin Siddiqi នាយិកាធនាគារអភិវឌ្ឍន៍អាស៊ី ប្រចាំប្រទេសកម្ពុជា** អមដោយ **លោក ឡុង ពិសិដ្ឋ មន្ត្រីជាន់ខ្ពស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងជាប្រធានគម្រោង ASCEP ប្រចាំប្រទេសកម្ពុជា** និងគណៈប្រតិភូក្រុមបេសកកម្មនៃធនាគារអភិវឌ្ឍន៍អាស៊ី ដោយមានការចូលរួមពីតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងតំណាងសមាជិកសហគមន៍កសិកម្ម។



រូបភាព៖ សកម្មភាពចូលរួមអមដំណើរប្រតិភូធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដើម្បីចូលរួមសម្រប-សម្រួលនិងពិនិត្យវឌ្ឍនភាពរបស់សហគមន៍កសិកម្ម នៅខេត្តកំពង់ធំ និងខេត្តសៀមរាប។

## សិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០២៥-២០៣០ ផ្នែកវិស័យហិរញ្ញវត្ថុមិនមែនធនាគារ

នាថ្ងៃសុក្រ ១៤រោចខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់ រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវា**ហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) បានអញ្ជើញជាអធិបតីបើកកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០២៥-២០៣០ ផ្នែកវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។ សិក្ខាសាលានេះ បានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០២៥-២០៣០ ឱ្យបានទូលំទូលាយដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ជាមួយគ្នានេះ កម្មវិធីសិក្ខាសាលា ក៏មានការអញ្ជើញចូលរួមធ្វើបទបង្ហាញពីតំណាងនិយ័តករ-អង្គភាពក្រោមឱវាទ **អ.ស.ហ.** ពីវិស័យរៀងៗខ្លួនផងដែរ។

កម្មវិធីសិក្ខាសាលានេះ មានការអញ្ជើញចូលរួមពីតំណាងថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនិយ័តករ-អង្គភាពក្រោមឱវាទ **អ.ស.ហ.**, តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ និងតំណាងរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។



រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០២៥-២០៣០ ផ្នែកវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

## សកម្មភាពមន្ត្រីជំនាញនៃ ន.ប.ធ. ចុះត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្ម ដែលស្ថិតនៅខេត្តតាកែវ

ចាប់ពីថ្ងៃអាទិត្យ ៩រោច ដល់ថ្ងៃអង្គារ ១២រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១០-១២ ខែឧសភា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាត និងការចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក ហេង បញ្ញា ប្រធានការិយាល័យគ្រប់គ្រងបរធនបាលកិច្ចសង្គម និងបុគ្គលនៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច** បានដឹកនាំមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្ម ដែលស្ថិតនៅខេត្តតាកែវ ដើម្បីពិនិត្យនិងផ្ទៀងផ្ទាត់អត្តសញ្ញាណបរធននៃទ្រព្យសម្បត្តិបរធនបាលកិច្ចដែលបានស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ចនៅ **ន.ប.ធ.** ដែលកំពុងធ្វើប្រតិបត្តិការដោយបរធនបាលដែលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.**។



រូបភាព៖ សកម្មភាពមន្ត្រីជំនាញនៃ ន.ប.ធ. ចុះត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្ម ដែលស្ថិតនៅខេត្តតាកែវ។

## ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពី “ការលើកកម្ពស់ការយល់ដឹង និងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា” រវាង ន.ប.ធ. និងសាកលវិទ្យាល័យធនធានមនុស្ស (ស.ធ.ម.)

នាព្រឹកថ្ងៃចន្ទ ២កើតខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ ត្រូវនឹងថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (**អ.ស.ហ.**) និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យធនធាន

មនុស្ស (**ស.ធ.ម.**) បានចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ស្តីពី "ការលើកកម្ពស់ការយល់ដឹង និងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាព **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងលោកបណ្ឌិត **ជា សុភាព សាកលវិទ្យាធិការនៃ ស.ធ.ម.** នៅទីស្តីការ **អ.ស.ហ.**។ ការចុះអនុស្សរណៈនៃការយោគយល់គ្នានេះ មានគោលបំណងដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងផ្សព្វផ្សាយអំពីវិស័យបរធនបាលកិច្ចដល់និស្សិតនៃ **ស.ម.ធ.** ឱ្យបានកាន់តែទូលំទូលាយ ព្រមទាំងផ្តល់ការគាំទ្រក្នុងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យបរធនបាលកិច្ចនៅកម្ពុជាផងដែរ។ ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នានេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងតំណាងជាន់ខ្ពស់នៃនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.**, ថ្នាក់ដឹកនាំនៃ **ស.ម.ធ.** និងថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** ព្រមទាំងថ្នាក់ដឹកនាំ និងតំណាងក្រុមហ៊ុនបរធនបាល ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក ក្រុមហ៊ុនវាយតម្លៃ និងក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ព្រមទាំងបុគ្គលពាក់ព័ន្ធ ដែលផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច។



រូបភាព៖ ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ស្តីពី "ការលើកកម្ពស់ការយល់ដឹង និងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" រវាង ន.ប.ធ. និងសាកលវិទ្យាល័យធនធានមនុស្ស (ស.ធ.ម.)។

## កិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សាស្តីពី "ការពិនិត្យឡើងវិញនិងការវិភាគមុខងារ និងរចនាសម្ព័ន្ធ អ.ស.ហ. ពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុនិងបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ"

នារសៀលថ្ងៃចន្ទ ២កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ ត្រូវនឹងថ្ងៃទី១៨ខែឧសភា ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សាស្តីពី "ការពិនិត្យឡើងវិញនិងការវិភាគមុខងារនិងរចនាសម្ព័ន្ធ **អ.ស.ហ.** ពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុនិងបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ" ក្រោមការដឹកនាំរបស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា អ.ស.ហ.** នៅទីស្តីការ **អ.ស.ហ.**។



រូបភាព៖ កិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សាស្តីពី "ការពិនិត្យឡើងវិញនិងការវិភាគមុខងារនិងរចនាសម្ព័ន្ធ អ.ស.ហ. ពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុនិងបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ"។

## សិក្ខាសាលាចែករំលែកបទពិសោធស្តីពី "វឌ្ឍនភាព និងទិសដៅបរិវត្តកម្មឌីជីថលនៅកម្ពុជា"

រសៀលថ្ងៃអង្គារ ៣កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ ត្រូវនឹងថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានចូលរួមជាអធិបតី ក្នុងកម្មវិធីសិក្ខាសាលាចែករំលែកបទពិសោធស្តីពី "វឌ្ឍនភាព និងទិសដៅបរិវត្តកម្មឌីជីថលនៅកម្ពុជា" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ម៉ី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (**អ.ស.ហ.**)។ កម្មវិធីនេះមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាតំណាងនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.** ព្រមទាំងក្រុមហ៊ុន និងតួអង្គពាក់ព័ន្ធ នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។



រូបភាព៖ សិក្ខាសាលាចែករំលែកបទពិសោធស្តីពី "វឌ្ឍនភាព និងទិសដៅបរិវត្តកម្មឌីជីថលនៅកម្ពុជា"។

## កិច្ចប្រជុំពិនិត្យពិភាក្សាលើការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់និងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈឯកទេសនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ)

នាព្រឹកថ្ងៃពុធ ៤កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៦, ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**, **លោក យុន វាសនា** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យពិភាក្សាលើការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់និងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈឯកទេសនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) និងការចែករំលែកបទពិសោធន៍ពាក់ព័ន្ធការងារវិភាគមុខងារនិងរចនាសម្ព័ន្ធ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ឯក ចន្ថា អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន កសហវ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន និងអង្គភាពក្រោមឱវាទ **កសហវ** នៅទីស្តីការ **កសហវ**។



រូបភាព៖ សិក្ខាសាលាចែករំលែកបទពិសោធស្តីពី "វឌ្ឍនភាព និងទិសដៅបរិវត្តកម្មឌីជីថលនៅកម្ពុជា"។

## ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករធានារ៉ាប់រងកម្ពុជា និងវិទ្យាស្ថានធានារ៉ាប់រងនិងហិរញ្ញវត្ថុ នៃប្រទេសអូស្ត្រាលី និងនូវែលហ្សេឡង់ (ANZIIF)"

នាព្រឹកថ្ងៃពុធ ៤កើតខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៦ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួម "ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករធានារ៉ាប់រងកម្ពុជា និងវិទ្យាស្ថានធានារ៉ាប់រងនិងហិរញ្ញវត្ថុ នៃប្រទេសអូស្ត្រាលី និងនូវែលហ្សេឡង់ (ANZIIF)" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ច័ន្ទភិរុ** អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា ព្រមទាំងមានការចូលរួមពី ឯកឧត្តម លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ននានានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។



រូបភាព៖ ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករធានារ៉ាប់រងកម្ពុជា និងវិទ្យាស្ថានធានារ៉ាប់រងនិងហិរញ្ញវត្ថុ នៃប្រទេសអូស្ត្រាលី និងនូវែលហ្សេឡង់ (ANZIIF)"។

## កិច្ចប្រជុំជាមួយក្រុមបេសកកម្ម JICA លើការរៀបចំផែនការស្ទង់មតិលម្អិត សម្រាប់គម្រោងជំនួយបច្ចេកទេស ដំណាក់កាលទី២ របស់ធនាគារជាតិនៃកម្ពុជា

នារសៀលថ្ងៃពុធ ៤កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ ត្រូវនឹងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៦, ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក យុន វាសនា** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំជាមួយក្រុមបេសកកម្ម JICA លើការរៀបចំផែនការស្ទង់មតិលម្អិត សម្រាប់គម្រោងជំនួយបច្ចេកទេស ដំណាក់កាលទី២ របស់ធនាគារជាតិនៃកម្ពុជា ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ម៉ី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (**អ.ស.ហ.**) និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាតំណាងនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.** នៅទីស្តីការ **អ.ស.ហ.**។



រូបភាព៖ កិច្ចប្រជុំជាមួយក្រុមបេសកកម្ម JICA លើការរៀបចំផែនការស្ទង់មតិលម្អិត សម្រាប់គម្រោងជំនួយបច្ចេកទេស ដំណាក់កាលទី២ របស់ធនាគារជាតិនៃកម្ពុជា។

## កម្មវិធីបញ្ជ្រាបការយល់ដឹងស្តីពី "ការដាក់ឱ្យអនុវត្តចំណាយវិនិយោគថវិកាថ្នាក់ជាតិក្នុងប្រទេសតាម FMIS និងការកត់ត្រាទិន្នន័យចំណាយគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ក្នុង FMIS ជូនក្រសួង-ស្ថាប័ន និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធពេញលេញ"

នាព្រឹកថ្ងៃព្រហស្បតិ៍ ៥កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ ត្រូវនឹងថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៦, **លោក យុន វាសនា** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមកម្មវិធីបញ្ជ្រាបការយល់ដឹងស្តីពី "ការដាក់ឱ្យអនុវត្តចំណាយវិនិយោគថវិកាថ្នាក់ជាតិក្នុងប្រទេសតាម FMIS និងការកត់ត្រាទិន្នន័យចំណាយគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ក្នុងFMIS ជូនក្រសួង-ស្ថាប័ន និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធពេញលេញ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** (**កសហវ**) និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំតំណាងក្រសួង-ស្ថាប័ន-អង្គភាពក្រោមឱវាទ **កសហវ** នៅសណ្ឋាគារ រ៉ាហ្វ៊ែលឡឺរ៉ូយ៉ាល់។



រូបភាព៖ កម្មវិធីបញ្ជ្រាបការយល់ដឹងស្តីពី "ការដាក់ឱ្យអនុវត្តចំណាយវិនិយោគថវិកាថ្នាក់ជាតិក្នុងប្រទេសតាម FMIS និងការកត់ត្រាទិន្នន័យចំណាយគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ក្នុងFMIS ជូនក្រសួង-ស្ថាប័ន និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធពេញលេញ"។

## ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារទីស្នាក់ការកណ្តាលថ្មីរបស់អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នាព្រឹកថ្ងៃព្រហស្បតិ៍ ៥កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច បានអញ្ជើញចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារទីស្នាក់ការកណ្តាលថ្មីរបស់អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅអគារទីស្នាក់ការកណ្តាលរបស់អគ្គនាយកដ្ឋានពន្ធដារ។



រូបភាព៖ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារទីស្នាក់ការកណ្តាលថ្មីរបស់អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## សកម្មភាពរបស់មន្ត្រីជំនាញនៃ ន.ប.ធ. ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ក្រុមហ៊ុន ឡាយអិន ត្រាស់ (ខេមបូឌា) ឯ.ក ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំបន្តអាជ្ញាបណ្ណពី ន.ប.ធ.

ព្រឹកថ្ងៃព្រហស្បតិ៍ ៥កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ ត្រូវនឹងថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោកស្រី ស៊ិន សុមាល័យ អនុប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ចនៃ ន.ប.ធ.** បានដឹកនាំមន្ត្រីជំនាញចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ក្រុមហ៊ុន ឡាយអិន ត្រាស់ (**ខេមបូឌា**) ឯ.ក ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំបន្តអាជ្ញាបណ្ណក្រុមហ៊ុនបរធនបាលសម្រាប់ប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម។




រូបភាព៖ សកម្មភាពរបស់មន្ត្រីជំនាញនៃ ន.ប.ធ. ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ក្រុមហ៊ុន ឡាយអិន ត្រាស់ (ខេមបូឌា) ឯ.ក ដើម្បីពិនិត្យនិងផ្ទៀងផ្ទាត់ការស្នើសុំបន្តអាជ្ញាបណ្ណពី ន.ប.ធ.។

## សកម្មភាពមន្ត្រីជំនាញនៃ ន.ប.ធ. ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ក្រុមហ៊ុន អឺរ៉ាស៊ា ត្រាស ឯ.ក ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំផ្លាស់ប្តូរទីស្នាក់ការថ្មី

នារសៀលថ្ងៃព្រហស្បតិ៍ ៥កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបេធនបាលកិច្ច (**ន.ប.ធ.**), **លោកស្រី ស៊ិន សុមាល័យ អនុប្រធាននាយកដ្ឋានចុះបញ្ជីបេធនបាលកិច្ចនៃ ន.ប.ធ.** បានដឹកនាំមន្ត្រីជំនាញចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ក្រុមហ៊ុន អឺរ៉ាស៊ា ត្រាស ឯ.ក ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំផ្លាស់ប្តូរទីស្នាក់ការថ្មី។




**រូបភាព៖** សកម្មភាពមន្ត្រីជំនាញនៃ ន.ប.ធ. ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ក្រុមហ៊ុន អឺរ៉ាស៊ា ត្រាស ឯ.ក ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំផ្លាស់ប្តូរទីស្នាក់ការថ្មី។

## វេទិកាវិនិយោគសកលអាស៊ាន

នៅថ្ងៃព្រហស្បតិ៍ ៥កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ ត្រូវនឹងថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបេធនបាលកិច្ច (**ន.ប.ធ.**), **លោក ហេង សំអុល ប្រធានការិយាល័យសហប្រតិបត្តិការនៃនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ, កញ្ញា ហ៊ឹម រី អនុប្រធានការិយាល័យគ្រប់គ្រងបេធនបាលកិច្ចហិរញ្ញវត្ថុនៃនាយកដ្ឋានចុះបញ្ជីបេធនបាលកិច្ច, និង កញ្ញា ស៊ូ ចាន់លីណា មន្ត្រីនៃការិយាល័យអធិការកិច្ច និងពង្រឹងការអនុវត្តច្បាប់នៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ចនៃ ន.ប.ធ.** ត្រូវបានចាត់ឱ្យបានចូលរួមវេទិកាវិនិយោគសកលអាស៊ាន (ASEAN Global Investment Forum) ដែលបានរៀបចំឡើងដោយស្ថាប័នវិនិយោគិន (Institutional Investor) នៅប្រទេសសិង្ហបុរី ដែលជាស្ថាប័នអន្តរជាតិឈានមុខគេក្នុងការផ្តល់ទស្សនវិស័យ ក៏ដូចជាការយល់ដឹងស៊ីជម្រៅលើការវិនិយោគសកលដល់បណ្តាស្ថាប័នវិនិយោគិនទូទាំងសកលលោក។

វេទិកានេះ ត្រូវបានរៀបចំឡើង ក្នុងគោលបំណង ប្រមូលផ្តុំថ្នាក់ដឹកនាំ និងតំណាងជាន់ខ្ពស់មកពីបណ្តាស្ថាប័នហិរញ្ញវត្ថុ និងវិនិយោគិន ស្ថាប័ននៃសន្តិសុខសង្គម (Social Security), ប្រាក់សោធននិវត្តន៍ (Pension), ធានារ៉ាប់រង (Insurance), មូលនិធិបម្រុងរដ្ឋាភិបាល (Government/Sovereign Reserve Fund), និងអាជ្ញាធរហិរញ្ញវត្ថុ ក៏ដូចជាស្ថាប័នវិនិយោគសាធារណៈ និងឯកជនផ្សេងៗនៅតាមបណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ និងសកលលោក ដើម្បីពិភាក្សាក៏ដូចជាចែករំលែកចំណេះដឹង និងបទពិសោធន៍ទាក់ទងនឹងការអភិវឌ្ឍ និងការរក្សាឧត្តមភាព លំដាប់ថ្នាក់ពិភពលោក ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ស្ថាប័នសម្រាប់ការវិនិយោគរយៈពេលវែង។ វេទិកាខាងលើ មានការចូលរួមពីតំណាងធនាគារកណ្តាល អាជ្ញាធរសេវាហិរញ្ញវត្ថុ វិនិយោគិនស្ថានប័ន ស្ថាប័នហិរញ្ញវត្ថុ និងវិនិយោគ ព្រមទាំងអ្នកជំនាញសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជាធុរជននៃបណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ និងលកលលោក។




**រូបភាព៖** វេទិកាវិនិយោគសកលអាស៊ាន។

## កម្មវិធី "Asia Tech x Singapore ប្រចាំឆ្នាំ២០២៦"

នាថ្ងៃពុធ-សុក្រ ៤-៦កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ ត្រូវនឹងថ្ងៃទី២០-២២ ខែឧសភា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបេធនបាលកិច្ច (**ន.ប.ធ.**), **លោក ម៉េង ឈុនលី** និង **លោក ហឿន លីហួរ មន្ត្រីជំនាញការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យានៃនាយកដ្ឋានកិច្ចការទូទៅ** មានកិត្តិយសត្រូវបានចាត់ឱ្យចូលរួមកម្មវិធី "Asia Tech x Singapore ប្រចាំឆ្នាំ២០២៦" នៅប្រទេសសិង្ហបុរី។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីសិក្សាឈ្វេងយល់ និងដកស្រង់បទពិសោធន៍អំពីនិន្នាការ និងការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗនៅក្នុងតំបន់ និងពិភពលោក ជាពិសេសពាក់ព័ន្ធនឹងបញ្ញាសិប្បនិម្មិត (AI), សន្តិសុខសាយប័រ (Cybersecurity), បច្ចេកវិទ្យាក្លោដ (Cloud Computing), រដ្ឋាភិបាលឌីជីថល (Digital Governance) និងបច្ចេកវិទ្យាឌីជីថលសំខាន់ៗផ្សេងទៀតដែលកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល។




រូបភាព៖ កម្មវិធី "Asia Tech x Singapore ប្រចាំឆ្នាំ២០២៦"។

## សិក្ខាសាលាផ្សព្វផ្សាយអំពី "គោលការណ៍ណែនាំស្តីពីវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនក្នុងវិស័យបរធនបាលកិច្ច និង សេចក្តីណែនាំស្តីពីវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនក្នុងក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម"

នៅព្រឹកថ្ងៃចន្ទ ៩កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៦ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (**ស.ហ.ក**) បានសហការរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពី "គោលការណ៍ណែនាំស្តីពីវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនក្នុងវិស័យបរធនបាលកិច្ច និង សេចក្តីណែនាំស្តីពីវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនក្នុងក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម" ដល់បរធនបាល និងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និង **ឯកឧត្តម ហេង ប៊ុមករា** ប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នៅអាគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។

សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណង ក្នុងការលើកកម្ពស់ការយល់ដឹង និងបង្កភាពងាយស្រួលដល់ការអនុវត្តមុខងាររបស់ប្រតិបត្តិករក្នុងវិស័យបរធនបាលកិច្ច និងជាបុគ្គលរាយការណ៍ដែលត្រូវប្រតិបត្តិតាមវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនក្នុងវិស័យបរធនបាលកិច្ច (KYC) និង វិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន (CDD) ក្នុងក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ព្រមទាំងដើម្បីត្រៀមខ្លួន និងបន្តរក្សាបាននូវលទ្ធផលវាយតម្លៃវិស័យបរធនបាលកិច្ចថាជាវិស័យដែលមានហានិភ័យកម្រិតទាប ដូចមានក្នុងរបាយការណ៍ស្តីពីការវាយតម្លៃហានិភ័យកម្រិតទាប ដូចមានក្នុងរបាយការណ៍ស្តីពីការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មលើកទី២ (NRA II) កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦។ ការរៀបចំសិក្ខាសាលានេះ អនុលោមតាមអនុសាសន៍ និងស្តង់ដាអន្តរជាតិរបស់ក្រុមការងារហិរញ្ញវត្ថុ (FAFT), ក្រុមត្រួតពិនិត្យនិងវាយតម្លៃ នៃវេទិកាសកលស្តីពីតម្លាភាព និងការផ្លាស់ប្តូរព័ត៌មានដើម្បីគោលបំណងពន្ធ (Global Forumនៃ OECD) ក្រុមការងារពាក់ព័ន្ធនឹងការរៀបចំស្ថិរភាពហិរញ្ញវត្ថុ (Financial Stability)។



រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយអំពី "គោលការណ៍ណែនាំស្តីពីវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនក្នុងវិស័យបរធនបាលកិច្ច និង សេចក្តីណែនាំស្តីពីវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនក្នុងក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម"។

## សកម្មភាពចូលរួមអមដំណើរ និងសម្របសម្រួលសកម្មភាពសម្រាប់ដំណើរទស្សនកិច្ចរបស់ក្រុមប្រឹក្សាភិបាល និងប្រតិភូរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) លើសកម្មភាពដាំដុះបន្លែរបស់សមាជិកសហគមន៍កសិកម្មសុវត្ថិភាពធម្មជាតិដែលទទួលហិរញ្ញប្បទានពីគម្រោង ACSEP ក្នុងខេត្តសៀមរាប

នាថ្ងៃអង្គារ ១០កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ ត្រូវនឹងថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៦ ដោយទទួលបានការចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធានគ្រប់គ្រងនៃគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សមាសភាគទី១ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, **លោក ប៉ូ សំអាង ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងជាប្រធានផ្នែកប្រតិបត្តិការ នៃគម្រោង** ACSEP-PIU1 អមដោយសហការី បានអញ្ជើញចូលរួមអមដំណើរ និងសម្របសម្រួលសកម្មភាពសម្រាប់ដំណើរទស្សនកិច្ចរបស់ក្រុមប្រឹក្សាភិបាល និងប្រតិភូរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) លើសកម្មភាពដាំដុះបន្លែរបស់សមាជិកសហគមន៍កសិកម្មសុវត្ថិភាពធម្មជាតិដែលទទួលហិរញ្ញប្បទានពីគម្រោង ACSEP ក្នុងខេត្តសៀមរាប។

ជាលទ្ធផលបន្ទាប់ពីការពិភាក្សាយ៉ាងសកម្ម និងទស្សនៈកិច្ចផ្ទាល់តាមសួនបន្លែរបស់សមាជិក ប្រតិភូរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

មានការពេញចិត្តខ្លាំង និងវាយតម្លៃខ្ពស់លើប្រសិទ្ធភាពនៃការប្រើប្រាស់ឥណទានរបស់សមាជិកក្នុងក្របខ័ណ្ឌរបស់គម្រោង ACSEP ហើយបានលើកទឹកចិត្តសមាជិកខិតខំបន្ត ពិនិត្យលទ្ធភាព និងឱកាសក្នុងការពង្រីកការផលិតដើម្បីផ្គត់ផ្គង់ និងឆ្លើយតបតម្រូវការទីផ្សារបន្ថែមទៀត។



រូបភាព៖ សកម្មភាពចូលរួមអមដំណើរ និងសម្របសម្រួលសកម្មភាពសម្រាប់ដំណើរទស្សនកិច្ចរបស់ក្រុមប្រឹក្សាភិបាល និងប្រតិភូរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) លើសកម្មភាពដាំដុះបន្លែរបស់សមាជិកសហគមន៍កសិកម្មសុវត្ថិភាពធម្មជាតិដែលទទួលហិរញ្ញប្បទានពីគម្រោង ACSEP ក្នុងខេត្តសៀមរាប។

## សកម្មភាពមន្ត្រីជំនាញនៃ ន.ប.ធ. ចុះត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្ម ដែលស្ថិតនៅខេត្តតាកែវ, ខេត្តកំពង់ចាម, ខេត្តកណ្តាល និងរាជធានីភ្នំពេញ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់អត្តសញ្ញាណបរធននៃទ្រព្យសម្បត្តិបរធនបាលកិច្ចដែលបានស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ចនៅ ន.ប.ធ.

ចាប់ពីថ្ងៃព្រហស្បតិ៍ ៥កើត ដល់ថ្ងៃអង្គារ ១០កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២១-២៦ ខែឧសភា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាត និងការចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក ហេង បញ្ញា** ប្រធានការិយាល័យគ្រប់គ្រងបរធនបាលកិច្ចបុគ្គល និងសង្គម, **លោក ឆយ ច័ន្ទមករា** ប្រធានការិយាល័យគ្រប់គ្រងបរធនបាលកិច្ចសាធារណៈ និងពាណិជ្ជកម្ម និង **លោក អ៊ឹង ឡេង** ប្រធានការិយាល័យគ្រប់គ្រងបរធនបាលកិច្ចហិរញ្ញវត្ថុ នៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច បានដឹកនាំមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្ម ដែលស្ថិតនៅខេត្តតាកែវ, ខេត្តកំពង់ចាម, ខេត្តកណ្តាល និងរាជធានីភ្នំពេញ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ អត្តសញ្ញាណបរធននៃទ្រព្យសម្បត្តិបរធនបាលកិច្ចដែលបានស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ចនៅ **ន.ប.ធ.** ដែលកំពុងធ្វើប្រតិបត្តិការដោយក្រុមហ៊ុនបរធនបាលដែលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.**។



រូបភាព៖ សកម្មភាពមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្ម ដែលស្ថិតនៅខេត្តតាកែវ, ខេត្តកំពង់ចាម, ខេត្តកណ្តាលនិងរាជធានីភ្នំពេញ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់អត្តសញ្ញាណបរធននៃទ្រព្យសម្បត្តិបរធនបាលកិច្ចដែលបានស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ចនៅ **ន.ប.ធ.**។

## កិច្ចប្រជុំបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃព្រហស្បតិ៍ ១២កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៦, **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោក យុន វាសនា** អគ្គនាយករងនៃ **ន.ប.ធ.** និងសហការីបានអញ្ជើញចូលរួមកិច្ចប្រជុំបច្ចេកទេស នៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ស្តីពីការអនុវត្តថវិកាប្រចាំឆ្នាំ២០២៥ របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា **អ.ស.ហ.** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាតំណាងនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.** តាមរយៈប្រព័ន្ធអនឡាញ Zoom ។



រូបភាព៖ កិច្ចប្រជុំបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។

# សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់កសិធុរកិច្ច សមាជិកសហគមន៍កសិកម្ម និងកសិករចិញ្ចឹមមាន់"

ចាប់ពីថ្ងៃពុធ ១១កើត ដល់ថ្ងៃសុក្រ ១៣កើត ខែជេស្ឋ ឆ្នាំមមី សប្តស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៦ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១ (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់កសិធុរកិច្ច សមាជិកសហគមន៍កសិកម្ម និងកសិករចិញ្ចឹមមាន់" ក្រោមការដឹកនាំរបស់ **លោក ប៉ូ សំអាង ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការនៃ ន.ប.ធ.** និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1 តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីសាវតារ និងបច្ចុប្បន្នភាពនៃគម្រោង ACSEP ជាពិសេសគោលនយោបាយឥណទាន បែបបទ និងនីតិវិធីក្នុងការរៀបចំស្នើសុំឥណទាននៃគម្រោង ACSEP ដែលជាឥណទានមានលក្ខខណ្ឌអនុគ្រោះ និងគាំទ្រដល់សហគមន៍កសិកម្ម និងកសិធុរកិច្ច ដល់សមាជិកនៃសហគមន៍កសិកម្មនរិទ្ធចម្រើនផល សហគមន៍កសិកម្មរស្មីស្តីក្រោម សហគមន៍កសិកម្មសម្រស់មុខរាហ៍ សហគមន៍កសិកម្មពន្លឺរស្មីស្តុកប្រវឹក និងសហគមន៍កសិកម្មអាងកំពីងពួយ ដែលស្ថិតនៅស្រុកឯកភ្នំ ស្រុករុក្ខគិរី និងស្រុកបាណន់ ខេត្តបាត់ដំបង ដែលមានបំណងស្វែងរកហិរញ្ញប្បទាន ដើម្បីគាំទ្រ និងពង្រីកអាជីវកម្មរបស់ខ្លួន។

សិក្ខាសាលានេះ មានការចូលរួមដោយ សមាជិកសហគមន៍កសិកម្ម និងកសិធុរកិច្ចខាងលើ, មន្រ្តី និងទីប្រឹក្សារបស់គម្រោង ACSEP-PIU1, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបង, និងស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន៖ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) និងធនាគារស្ថាបនា (Sathapana Bank)។




រូបភាព៖ សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់កសិធុរកិច្ច សមាជិកសហគមន៍កសិកម្ម និងកសិករចិញ្ចឹមមាន់"។